# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

**Kampuchea Action to Promote Education (KAPE)**

## សេចក្តីជូនដំណឹងស្តីពី

**ការអញ្ជើញចូលរួមដេញថ្លៃសម្ភារព័ត៌មានវិទ្យា** (Tablets, Workstation (Mini PC), LCD Projector and Computer Laptop) **សម្រាប់គម្រោង "លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស" អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ក្រោមជំនួយថវិកាដោយ អង្គការ មូលនិធិកុមារកូរ៉េ (ប្រទេសកូរ៉េ ខាងត្បូង)**

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ហៅកាត់ថា KAPE) សូមប្រកាសបើកចំហដល់ក្រុមហ៊ុន ម្ចាស់សហគ្រាសសាជីវកម្ម/អាជីវករនិងអ្នកទទួលផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យាក្នុងស្រុកទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្រុមហ៊ុន សហគ្រាសសាជីវកម្ម/អាជីវករស្ថិតក្នុងបញ្ជីខ្មៅ ឬត្រូវហាមឃាត់ដោយតុលាការឱ្យបានជ្រាបថា៖ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា/គម្រោង"**លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស**"នឹងប្រកាសដាក់ឱ្យចូលរួមដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុន សហគ្រាសសាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យារួមមាន៖ (Tablets, Workstation (Mini PC), LCD Projector and Computer Laptop) សម្រាប់ផ្តល់ជូនសាលារៀនគោលដៅរបស់គម្រោងស្ថិតនៅក្នុងរាជធានីភ្នំពេញ និងនៅក្នុងខេត្តកណ្តាល សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥នេះ ។

ក្រុមហ៊ុន សហគ្រាសសាជីវកម្ម ឬអាជីវករ និងអ្នកទទួលផ្គត់ផ្គង់ការសម្ភារព័ត៌មានវិទ្យា ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន សហគ្រាសសាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ព័ន្ធភាពតែមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

ក្រុមហ៊ុន សហគ្រាសសាជីវកម្ម/អាជីវករ និងអ្នកទទួលផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ដែលមានចំណាប់អារម្មណ៍ សូមធ្វើការទាក់ទងមកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ផ្នែករដ្ឋបាល/លទ្ធកម្ម) ដើម្បីសាកសួរព័ត៌មានអំពីការចូលរួមដេញថ្លៃ និងស្តីពីនិតិវិធីព្រមទាំងសេចក្តីណែនាំក្នុងការដាក់ពាក្យស្នើសុំចូលរួមដេញថ្លៃមានដូចខាងក្រោម៖

1. ការទទួលឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃចាប់ពីថ្ងៃទី០២ ដល់ ថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០២៤ វេលាម៉ោង ៨:៣០នាទី ព្រឹក តាមរយៈសារអេឡិចត្រូនិច (អ៊ីមែលជូនភ្ជាប់ខាងក្រោម)។
2. ការតម្រង់ទិសអំពីនិតិវិធីនៃការដេញថ្លៃធ្វើទៅតាមរយៈអនឡាញ (Zoom Meet) នឹងប្រព្រឹត្តិទៅនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង៩:៣០នាទី ព្រឹក(ទីកន្លែង៖ ការិយាល័យកណ្តាលអង្គការ ខេប)។
3. ការទទួលកញ្ចប់ឯកសារ និងពាក្យស្នើសុំចូលរួមដេញថ្លៃ **ចាប់ពីថ្ងៃទី០៩** រហូតដល់ **ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២៤** វេលាម៉ោង ៥:០០ល្ងាច ជាកំហិត។
4. អ្នកចូលរួមដេញថ្លៃទាំងអស់តម្រូវឱ្យដាក់តំកល់ប្រាក់កក់ចំនួន៥%នៃតម្លៃដេញថ្លៃសរុប ក្នុងការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ដើម្បីទទួលបានសិទ្ធិចូលរួមបើកកញ្ចប់ដេញថ្លៃ។ ក្រោយការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើក្រុមហ៊ុន សហគ្រាសសាជីវកម្ម/អាជីវករ និងអ្នកទទួលផ្គត់ផ្គង់ណាដែលមិនបានឈ្នះជាប់ក្នុងការដេញថ្លៃនោះទេ អង្គការនឹងបង្វែរទឹកប្រាក់កក់គ្រប់ចំនួនទាំងអស់ត្រឡប់ជូនទៅឱ្យក្រុមហ៊ុនវិញ ក្នុងរយៈពេលយឺតបំផុតមួយសប្តាហ៍ក្រោយពេលដេញថ្លៃរួច។
5. ការប្រជុំបើកកញ្ចប់ដេញថ្លៃត្រូវរៀបចំធ្វើឡើងនៅការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពង់ចាម /ក្រុងកំពង់ចាម។

6. រាល់ឯកសារសម្រង់តម្លៃ និងពាក្យស្នើសុំចូលរួមការដេញថ្លៃ ត្រូវច្រកចូលក្នុងស្រោមរួចបិទជិត (ផ្លុំបេ) ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន ម្ចាស់សហគ្រាសសាជីវកម្ម /អាជីវកម្ម នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ហៅកាត់ថា ខេប) តាមអាសយដ្ឋានខាងលើ។ រាល់ឯកសារសម្រង់តម្លៃដេញថ្លៃទាំងអស់ ត្រូវរាប់បញ្ចូលនូវប្រាក់ពន្ធអាករលើតម្លៃបន្ថែម ១០% និងការបញ្ចុះតម្លៃរួចជាស្រេចផងដែរទៅតាមមុខសម្ភារព័ត៌មានវិទ្យានីមួយៗ ហើយមិនអនុញ្ញាតឱ្យដាក់ផ្ញើមកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល)ជាដាច់ខាត។
7. រាល់ឯកសារសម្រង់តម្លៃនិងពាក្យស្នើសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យកណ្តាលរបស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ និងមិនបានដាក់ដំកល់ប្រាក់កក់ ៥% ទៅតាមការណែនាំដូចមានចែងខាងលើ ត្រូវបានចាត់ទុកជាអាសាបង់ និងទុកជានិរាករណ៍។
8. អ្នកចូលរួមដេញថ្លៃទាំងអស់ ដែលមានសិទ្ធិចូលរួមដេញថ្លៃ ត្រូវបានអង្គការផ្ញើលិខិតអញ្ជើញជាផ្លូវការ ដើម្បីមកចូលរួមប្រជុំដោយចំហក្នុងការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមានសិទ្ធិចូលរួមហើយ តែមិនបានមកចូលរួមប្រជុំបើកសម្រង់តម្លៃទាន់ពេលវេលាបានកំណត់ អវត្តមាន ឬក៏មកយឺតរយៈពេល ១៥ នាទី ឯកសារដាក់ដេញថ្លៃនោះនឹងមិនអនុញ្ញាតឱ្យដាក់បញ្ចូលក្នុងការបើកឡើយ។
9. ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ ដែលមកក្នុងនាមជាអ្នកតំណាងក្រុមហ៊ុន ឬអាជីវករ និងអ្នកផ្គត់ផ្គង់ ត្រូវតែមានកាន់លិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន ម្ចាស់សហគ្រាស/អាជីវកម្ម។

**អសយដ្ឋានទំនាក់ទំនងសាកសួរព័ត៌មានផ្សេងៗ៖**


- ការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ហៅកាត់ថា ខេប )
- អាសយដ្ឋាន ៖ ក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម/ក្រុងកំពង់ចាម
- ឈ្មោះ ៖ លោកឈួន សារ៉ាន ជាប្រធានរដ្ឋបាល និងធនធានមនុស្ស
- ទូរសព្ទ ៖ ០១២ ៧៥២ ៥៥៣, ០៩៦ ៤៦៤ ៧៧៧៧, ០៩៧ ៦៩៨ ៨៤៨៤
- អ៊ីមែល (To) ៖ saran@kapekh.org
- ចម្លងជូន (CCC) ៖ vanna@kapekh.org, sambath@kapekh.org, sophanak@kapekh.org, ladet@kapekh.org, dara.chhuon@kapekh.org, vannak_eng@kapekh.org, sokhea.mai@kapekh.org,


ថ្ងៃសុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
កំពង់ចាម, ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤

**នាយកប្រតិបត្តិ**

KAMPUCHEA ACTION TO PROMOTE EDUCATION ORG

**សៅ.វណ្ណា**